ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតត្រារបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល នៃក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៨៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតត្រារបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល នៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល ដើម្បីប្រើប្រាស់ជាផ្លូវការក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ២ .-**

ត្រារបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលមានវណ្ណពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្តាល និងមានអក្សរកាត់ជាភាសាខ្មែរថា "**គ.រ.ឌ.**" នៅផ្នែកខាងក្រោមរូបប្រាសាទអង្គរវត្តកំពូលបី។ ផ្នែកខាងលើមានឆ្លាក់អក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" ស្របតាមវណ្ណ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "**គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល**" ស្របតាមវណ្ណ និងនៅចន្លោះពាក្យទាំងពីរ មានរូបសញ្ញាការតភ្ជាប់អត់ខ្សែអមសងខាង។

ត្រាដែលមានខ្លឹមសារដូចមានចែងខាងលើ ជាឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០កើត ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច

ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ១ នៃសេចក្ដីសម្រេចលេខ ១១ សសរ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៣**
**ស្ដីពី ការបង្កើតត្រារបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល**
**នៃក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមឌីជីថល**